## ៣.សេវាកម្មដឹកជញ្ជូនទេសចរណ៍

| ល.រ | លក្ខណវិនិច្ឆ័យ | កំណត់ចំណាំ | ការវាយតម្លៃស្តង់ដា | ពិន្ទុ |
|---|---|---|---|---|
| ១ | • មានបុគ្គលិកបម្រើការទទួលបានការវាយតម្លៃ និងបញ្ជាក់ថាមានលក្ខណៈស្រប តាមកម្មវិធី CAMBODIA-CHINA READY | • សំដៅដល់ "បុគ្គលិក" ដែលផ្តល់សេវាកម្មដោយផ្ទាល់ដល់ភ្ញៀវ<br>• ឬបុគ្គលិកផ្នែកបណ្តុះបណ្តាលរបស់អាជីវកម្មផ្ទាល់<br>• ការវាយតម្លៃត្រូវផ្អែកលើស្ថានភាពជាក់ស្តែងតើគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវឬទេ? | • បុគ្គលិកប្រតិបត្តិការជួរមុខយ៉ាងហោច១០%(ធៀបនឹងចំនួនបុគ្គលិកក្នុងផ្នែកសរុប) មានការទទួលស្គាល់<br>• ឬបុគ្គលិកផ្នែកបណ្តុះបណ្តាលយ៉ាងហោច១រូប | • ១០ពិន្ទុៈ បំពេញតាមស្តង់ដា<br>• ១៥ពិន្ទុៈ ធ្វើលើសស្តង់ដា<br>• ៣០ពិន្ទុៈ ធ្វើលើសស្តង់ដារហូតចាប់ពី៨០%(ធៀបនឹងចំនួនសរុប) ឡើងទៅ |
| ២ | • មានគេហទំព័រជាភាសាចិនត្រឹមត្រូវ | • ជាគេហទំព័របង្ហាញអំពីការផ្សព្វផ្សាយផលិតផលនិងសេវាកម្ម<br>• ជាគេហទំព័រដែលអាចបញ្ជាទិញ កក់ និងអាចធ្វើសកម្មភាពធុរកិច្ចផ្សេងទៀត<br>• ជាគេហទំព័រដែលកំពុងដំណើរការ<br>• ការវាយតម្លៃត្រូវផ្អែកលើស្ថានភាពជាក់ស្តែងតើគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវការឬទេ? និងមានភាពទាក់ទាញឬទេ? | • មានគេហទំព័រជាភាសាចិន (Mandarin) និងអាចបើក<br>• មើលបានទាំងនៅកម្ពុជា និងប្រទេសចិន<br>• មានទម្រង់និងព័ត៌មានដូចគ្នានិងគេហទំព័រភាសាផ្សេងទៀតរបស់អាជីវកម្មដែរ<br>• មានបង្ហាញការសហការជាមួយក្រសួងទេសចរណ៍ និងកម្មវិធី CAMBODIA-CHINA READY | • ១០ពិន្ទុៈ បំពេញតាមស្តង់ដា<br>• ១៥ពិន្ទុៈ ធ្វើលើសស្តង់ដា |

| | | | | |
|---|---|---|---|---|
| ៣ | • ទម្រង់នៃការផ្តល់ព័ត៌មាន បកប្រែជាភាសាចិនត្រឹមត្រូវ | • ត្រូវពិនិត្យផ្តោតសំខាន់លើទីតាំង២កន្លែងគឺ៖ ចំណត និងមធ្យោបាយដឹកជញ្ជូន(ទាំងខាងក្នុង និងខាងក្រៅ)<br>• ត្រូវផ្តល់ព័ត៌មាន ៤ប្រភេទសំខាន់គឺ៖ ប្រភេទសេវាកម្មនិងតម្លៃ ព័ត៌មានអំពីគ្រោះថ្នាក់ជាយថាហេតុ ការហាមប្រាមដោយបញ្ញត្តិបទដ្ឋាន និងការជូនដំណឹងអំពីការចូលរួមដល់ការថែរក្សាបរិស្ថាននិងកិច្ចការសង្គម<br>• ការវាយតម្លៃផ្អែកលើវិធីសាស្ត្រនៃការផ្តល់ព័ត៌មាន ថាតើច្បាស់លាស់? និងគួរឱ្យចាប់អារម្មណ៍ឬទេ? | • មានប័ណ្ណព័ត៌មានជាភាសាចិន (Mandarin) អំពីប្រភេទសេវាកម្មនិងតម្លៃ ព័ត៌មានអំពីគ្រោះថ្នាក់ និងការហាមប្រាមដោយបញ្ញត្តិបទដ្ឋាននៅតាមចំណត និងមធ្យោបាយដឹកជញ្ជូន<br>• មានទម្រង់និងព័ត៌មានដូចគ្នានឹងប័ណ្ណព័ត៌មាន ឬមធ្យោបាយផ្តល់ព័ត៌មានជាភាសាផ្សេងទៀតរបស់អាជីវកម្មដែរ<br>• មានបង្ហាញការសហការជាមួយក្រសួងទេសចរណ៍ និងកម្មវិធី CAMBODIA-CHINA READY | • ១០ពិន្ទុ៖ បំពេញតាមស្តង់ដា<br>• ១៥ពិន្ទុ៖ ធ្វើលើសស្តង់ដា<br>• ៣០ពិន្ទុ៖ មានផ្តល់ព័ត៌មានទាំង ៤ប្រភេទជាភាសាចិន និងមានដាក់បង្ហាញនៅគ្រប់ទីកន្លែងសំខាន់ៗ |
| ៤ | • ព័ត៌មានសេវាអតិថិជន (Customer Service Information) | • សេវាកម្មអតិថិជនជាភាសាចិនត្រូវរក្សាឱ្យមានជាប់ជាប្រចាំ<br>• ការវាយតម្លៃផ្អែកលើសំនួរថាតើក្នុងករណីអាក្រក់បំផុត ភ្ញៀវទេសចរនិយាយភាសាចិននៅតែអាចទទួលបានសេវាកម្មបម្រើឬទេ? | • យ៉ាងហោចណាស់មានសេវាកម្មផ្តល់ព័ត៌មានជាភាសាចិន ២៤/៧ ចំពោះគេហទំព័រ និងក្នុងអំលុងម៉ោងប្រតិបត្តិការនៅចំណត និងក្នុងមធ្យោបាយដឹកជញ្ជូន<br>• មានការទូទាត់ជារូបិយបណ្ណយ័ន | • ០៥ពិន្ទុ៖ បំពេញតាមស្តង់ដា<br>• ១០ពិន្ទុ៖ ធ្វើលើសស្តង់ដា<br>• ២០ពិន្ទុ៖ សេវាកម្មជាភាសាចិនត្រូវបានផ្តល់ជូនជាប់ជាប្រចាំដូចភាសាដទៃ |

| | | | | |
|---|---|---|---|---|
| ៥ | • គុណភាពសេវាកម្ម | • សេវាកម្មដែលផ្តល់ជូនជាសេវាកម្មកម្រិតស្តង់ដា<br>• ការវាយតម្លៃផ្អែកលើស្តង់ដា និងការណែនាំរបស់ក្រសួងទេសចរណ៍ | • អាជីវកម្មត្រូវបំពេញយ៉ាងហោចឱ្យបានគ្រប់លក្ខខណ្ឌសុវត្ថិភាព ពេលចរាចរ ការសង្គ្រោះបឋម និងការសង្គ្រោះពេលមានហានិភ័យ | • ១០ពិន្ទុ៖ បំពេញតាមស្តង់ដា<br>• ២០ពិន្ទុ៖ ធ្វើលើសស្តង់ដា<br>• ៣០ពិន្ទុ៖ ធ្វើលើសស្តង់ដារហូតចាប់ពី៩០%(ធៀបនឹងចំនួនសរុប) ឡើងទៅ<br>• ការទទួលបានពានរង្វាន់ពិសេសសម្រាប់ធុរកិច្ចបៃតង(ប្រភេទរង្វាន់កិច្ចការពារបរិស្ថាន)៖ ទទួលបាន៣០ពិន្ទុ (មិនបន្ថែមទទួលបានពិន្ទុពេញនៅចំនុច ទី៣ពិន្ទុលើចំនុចខាងលើទេ) និងដោយគ្រាន់តែបង្ហាញថាមាន |